# ព្រះរាជក្រមលេខ ៩១៥ – ន.ស.

បានទ្រង់យល់ រដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រ ។

បានទ្រង់យល់ ក្រមពិភាក្សារដ្ឋប្បវេណី ។

បានទ្រង់យល់ ក្រមពាណិជ ។

បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ ៥២១ – ន.ស. ចុះថ្ងៃទី ២៦ សីហា គ.ស. ១៩៥៨ ស្ដីពីតាំងគណៈរដ្ឋមន្ត្រី ។

បានទ្រង់យល់ យោបល់នៃក្រុមប្រឹក្សាជាតិ ។

គណៈរដ្ឋមន្ត្រី បានយល់ព្រមផង ។

ត្រាស់បង្គាប់ដូចមានខាងក្រោម :

## ព្រះរាជក្រម ស្ដីពីតាំងបទបញ្ញត្តិ អំពីទំរង់ និងផលនៃកិច្ចសន្យាសម្រប និងអនុញ្ញាតឲ្យមានខ សម្របក្នុងរឿងជំនួញ

### ផ្នែកទី ១

### បទបញ្ញត្តិទូទៅ

មាត្រា ១.– កិច្ចសម្របគឺជាកិច្ចសន្យាមួយ ដែលគូសញ្ញាពីរនាក់ឬច្រើននាក់ ព្រមព្រៀងលើករឿងដែលទាស់គ្នា ទៅឲ្យអាជ្ញាកណ្ដាលមួយនាក់ឬច្រើននាក់ជំនុំជំរះ ហើយព្រមទទួលគោរពសាលក្រមដែលអាជ្ញាកណ្ដាលនេះ សម្រេចដោយស្មោះត្រង់ ។

មាត្រា ២ – គេមិនអាចធ្វើសម្របបាន ចំពោះរឿងអំណោយ: រឿងទ្រព្យបណ្ដាមតក ចំពោះបញ្ហាស្ដីពីសការៈសមត្ថភាពនៃមនុស្សមានការលែងលះគ្នា បំបែកកន្លែងប្ដីនឹងប្រពន្ធជាដើម ចំពោះប្រាក់ថ្លៃចិញ្ចឹមអាហារចំពោះការរក្សាកូន, ការទាក់ទងពុកនឹងកូន, ចំពោះការរលំជំនួញក្ដី ឬការលក់ឡាយឡុងទ្រព្យបែងចែកម្ចាស់

បំណុលក្តី (Faillite aux Liquidations Judiciaires) គឺមិនអាចសម្របបានឡើយ ចំពោះការពាស់ព័ន្ធ ដែលមានប៉ះពាល់ដល់ការរៀបរយសាធារណៈ ។

មាត្រា ៣.– ក្នុងព្រំដែននៃមាត្រា ២ ខាងលើ ជនគ្រប់រូបអាចធ្វើសម្របនូវសិទ្ធិរបស់ខ្លួនបាន ។

មាត្រា ៤.– ដើម្បីនឹងទុកជាបានការ ការសម្របត្រូវធ្វើតាមលក្ខណៈអក្សរ ដែលច្បាប់មានតំរូវទៅលើកិច្ចសន្យាទាំងឡាយដែលមានសំដែងនៅមាត្រា ៧៩១ និងមាត្រាតទៅទៀត នៃក្រមរដ្ឋប្បវេណីជាដើម ។

ភស្តុតាងមានតែចេញពីលាយលក្សណ៍អក្សរ ទុកជាសំបុត្រផ្ទាល់ខ្លួនក៏បាន តែត្រូវបញ្ជាក់ចំណុចដូចខាងក្រោមនេះ បើពុំនោះត្រូវទុកជាមោឃ ៖

១).– កម្មវត្ថុ រឿងវិវាទ,

២).– ចំនួន អាជ្ញាកណ្តាល,

៣).– នាម អាជ្ញាកណ្តាល,

៤).– ការិយបរិច្ឆេទ ដែលចុះហត្ថលេខាលើកិច្ចសម្រប ។

កិច្ចសន្យាមួយច្បាប់ ដែលមានចុះហត្ថលេខា គូសញ្ញាទាំងអស់ត្រូវប្រគល់ឲ្យគូសញ្ញានិមួយៗ ។

មាត្រា ៥.– ការសម្របអាចបញ្ជាក់អំពីច្បាប់ដែលត្រូវយកមកអនុវត្តន៍នីតិក្រមដែលត្រូវប្រតិបត្តិតាម ដើម្បីស៊ើបសួររឿងនោះនិងពិភាក្សា ព្រមទាំងភាសាដែលត្រូវប្រើ អំពីសាលាដែលមានសមត្ថកិច្ចត្រូវជំនុំជំរះរឿងវិវាទ ដែលកើតឡើងអំពីការបរិវត្តន៍នៃកិច្ចសម្របនេះ ដូចមានសំដែងនៅមាត្រា ២១ ។

កិច្ចសម្របនេះ អាចអនុញ្ញាតឲ្យអាជ្ញាកណ្តាលសម្រេចសេចក្តីជាអព្យាក្រិត គឺសម្រេចសេចក្តីដែលអាជ្ញាកណ្តាលយល់ឃើញថាជាការសមភាព អាចមិនឲ្យអាជ្ញា

កណ្តាលទទួលសម្បថស្បថតាមមាត្រា ១៤ បាន ។ វៀរលែងតែមានកិច្ចព្រមព្រៀងផ្សេងពីនេះ ភាសាដែលយកមកប្រើនៅពេលស៊ើបសួរ និងពេលពិភាក្សាចំពោះមុខអាជ្ញាកណ្តាល គឺភាសាជាតិនៃគូសញ្ញា ហើយបើគូសញ្ញាមានសញ្ជាតិផ្សេងៗពីគ្នា ត្រូវយកភាសាខ្មែរ ។

មាត្រា ៦.— លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះ អាជ្ញាកណ្តាលមានរយៈពេលបីខែ គិតពីថ្ងៃចុះហត្ថលេខាលើកិច្ចសម្របដើម្បីជំនុំជំរះ ។ ប៉ុន្តែតាមកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរគូសញ្ញាអាចពន្យារពេលបានបីខែម្តងៗ ពេលដែលមានអនុញ្ញាតឲ្យតាមកិច្ចសម្របដើម ឬតាមច្បាប់ បើគ្មាននិយាយក្នុងកិច្ចសម្របទេ ។

មាត្រា ៧.— អាជ្ញាកណ្តាលកាត់សេចក្តីតាមភាគច្រើន ។ សាលក្រមត្រូវតែងជាលាយលក្ខណ៍អក្សរ តាមភាសាដែលបានរើសយកសម្រាប់ពិភាក្សា ។ សាលក្រមដើមត្រូវមានចុះហត្ថលេខាភាគច្រើននៃអាជ្ញាកណ្តាល ។

គូសញ្ញាម្នាក់ៗ ត្រូវទទួលសេចក្តីចំលងសាលក្រមមួយ ដែលមានចុះហត្ថលេខាអាជ្ញាកណ្តាល ដូចមានសាលក្រមដើមដែរ ។

## ផ្នែកទី ២
## អំពីអាជ្ញាកណ្តាល

មាត្រា ៨.— ជនគ្រប់រូបពេញនីតិភាព ហើយមានសិទ្ធិរដ្ឋប្បវេណីអាចរើសធ្វើជាអាជ្ញាកណ្តាលបាន ។

ស្រីមានប្តី មិនចាំសុំអនុញ្ញាតពីប្តីទេ តែចៅក្រមនឹងអ្នករាជការក្នុងព្រះរាជរដ្ឋាភិបាល មុននឹងទទួលមុខក្រសួងធ្វើជាអាជ្ញាកណ្តាល ត្រូវសុំអនុញ្ញាតពីរដ្ឋមន្ត្រីដែលខ្លួននៅក្រោមបង្គាប់ ។

មាត្រា ៩.— ត្រូវទុកជាអសារឥតការ តាមរបៀបសាធារណៈ សាលក្រមអាជ្ញាកណ្តាលណា ដែលមានជនដូចខាងក្រោមនេះសំរេចផង:

១ — សមាជិករដ្ឋាភិបាលក្នុងការ ឬឥស្សរជនក្រុមនយោបាយដែលទើបមានព្រះរាជក្រឹត្យមួយកាយបញ្ជី ។

២.— ចៅហ្វាយខេត្តក្នុងការ ។

៣.— ចាងហ្វាងសាលាជំនុំជំរះ ឬនាយក្រុមអយ្យការ ។

៤.— សមាជិកក្រុមបេសកកម្មទូត ឬកុងស៊ុល ឬអគ្គការដូចនេះ ។

មាត្រា ១០.— វៀរលែងតែបទបញ្ញត្តនៃមាត្រា ១១ ខាងក្រោមនេះ មិនត្រូវបង្ខំឲ្យជនណាមួយទទួលមុខក្រសួងជាអាជ្ញាកណ្តាលឡើយ ។

បើអាជ្ញាកណ្តាលមួយនាក់ ឬច្រើននាក់ ដែលគូសញ្ញាបានរើសមិនព្រមទទួលតំណែងខ្លួន ហើយបើកិច្ចសម្រេចមិនបានបញ្ញត្តពីរបៀប ដែលត្រូវរើសអាជ្ញាកណ្តាលជំនួសវិញទេ ឬអំពីអាជ្ញាកណ្តាលគូឈ្មួយ ហើយបើគូសញ្ញាមិនព្រមព្រៀងយកឈ្មោះថ្មីតាមលាយលក្ខណ៍អក្សរទេ ចាងហ្វាងសាលាត្រូវតាំងអាជ្ញាកណ្តាល ដែលមានឈ្មោះក្នុងបញ្ជី ដែលមានបញ្ញត្តិក្នុងមាត្រា ១១ ចំនួនប៉ុន្មានឲ្យល្មមធ្វើជាក្រុមអាជ្ញាកណ្តាលឲ្យគ្រប់ចំនួនតាមបញ្ញត្តិក្នុងកិច្ចសម្រេច ។

តាមពាក្យសុំគូសញ្ញាណាមួយ ចាងហ្វាងជំនុំជំរះតាមសាលក្រមដែលអាចតវ៉ាចំពោះសាលាវិនិច្ឆ័យបាន តែមិនអាចផ្អាកមិនឲ្យសំរេចទេ ផ្លូវតវ៉ាឯទៀតមិនបើកឲ្យ ។

មាត្រា ១១.— ក្នុងកំណត់ ៩០ ថ្ងៃ ក្រោយដែលប្រកាសឲ្យប្រើព្រះរាជក្រមនេះ ប្រកាសរដ្ឋមន្ត្រីក្រសួងយុត្តិធម៌កំណត់បញ្ជីមួយមាននាម ៦០ នាក់ រើសយកក្នុងពួកឥស្សរៈជន ដែលគេស្គាល់ជាមានកិត្តិយសក្នុងព្រះរាជអាណាចក្រ ហើយដែលចេះដឹងទម្លាប់នឹងច្បាប់ជំនួញ ។ ចំនួនមនុស្សពាក់កណ្តាល ក្នុងឥស្សរៈជនដែលមានចុះនាមក្នុងបញ្ជីនេះ ត្រូវមានសញ្ជាតិជាខ្មែរជាដាច់ខាត ។

ឥស្សរៈជននេះ បង្កើតឡើងជាអាជ្ញាកណ្ដាលក្នុងសម្បថ ។ បញ្ជីរាយឈ្មោះឥស្សរៈជននេះ ត្រូវបិទជាភាសាបារាំង និងភាសាខ្មែរ នៅគ្រប់តែមាត់ទ្វារសាលាជំនុំពាណិជ្ជកម្មជំនួញ នៃព្រះរាជអាណាចក្រ ។

រាល់តែដើមឆ្នាំ អាជ្ញាកណ្ដាលនេះ ត្រូវទទួលសម្បថសច្ចាដែលមានសំដែងនៅមាត្រា ១៤ នៃព្រះរាជក្រមនេះ នៅចំពោះមុខសាលាជំនុំពាណិជ្ជកម្មក្រុងភ្នំពេញ ហើយត្រូវរើសតាំងប៉ុយមួយ ដែលត្រូវធ្វើអត្រាប្រាក់រង្វាន់ ។ នេះ ត្រូវមានប្រកាសរួមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង ហិរញ្ញវត្ថុយល់ព្រមផង ។ ក្នុងករណីណាក៏ដោយ ប្រាក់រង្វាន់នេះ មិនអាច កំរិតធំតូចតាមជំហៀររឿងរ៉ាវទេឡើយ ។

ការលុបឈ្មោះក្នុងបញ្ជីនេះ បណ្ដាលឲ្យបាត់កាតព្វកិច្ចឲ្យទទួលតំណែងជាអាជ្ញាកណ្ដាល ទោះគួរសញ្ញាពិនិត្យក្ដី ឬក៏មានសាលក្រមតាំងក្ដី ។ មានតែហេតុមកពីសុខភាពមិនបរិបូណ៌ ដែលពិនិត្យឃើញថាច្បាស់លាស់ ការមិនដឹងភាសាដែលត្រូវពិភាក្សា ឬហេតុដែលនៅក្នុងករណីណាមួយ ដែលមិនព្រមទទួលបានទេ ដែលអាចធ្វើឲ្យអាជ្ញាកណ្ដាល ក្នុងសម្បថជៀសរាងអំពីកាតព្វកិច្ចនេះបាន ។ ការរឹងទទឹងមិនព្រមទទួលដោយឥតហេតុ បណ្ដាលឲ្យលុបឈ្មោះចេញពីបញ្ជី មិនគិតពីជម្ងឺចិត្តផង ។

ប្រកាសកំរិតបញ្ជីអ្នកជំនាញការនេះ ត្រូវសំរេចអំពីរបៀបបទ ដែលត្រូវអនុវត្តន៍មាត្រានេះផង ។

មាត្រា ១២.— ការលុបឈ្មោះក្នុងបញ្ជី នូវអ្នកជំនាញក្នុងសម្បថមិនមែនឲ្យមានសិទ្ធិផ្ដាច់មុខទេ ។ មានតែសាលាជំនុំជំរះ ដែលត្រូវតាំងអាជ្ញាកណ្ដាលណាមួយ ឬអាជ្ញាកណ្ដាលអ្នករាយការណ៍ទេ ដែលអាចមានរើសយកក្នុងបញ្ជីនេះបាន ។

កិច្ចដែលអាជ្ញាកណ្ដាលព្រមទទួលកាន់តំណែងនូវ បណ្ដាលឲ្យអាជ្ញាកណ្ដាលនេះ មានកាតព្វកិច្ច និងជំនុំជំរះ ដោយគោរពតាម ខ. តាំងឡាយ នៃកិច្ចសម្រប

និងមានសិទ្ធិបើកប្រាក់ឆ្នើន ដែលគូសញ្ញាបានព្រមព្រៀងឲ្យ ឬប្រាក់ឆ្នើនដែលមានកំរិតតាមអត្រាពន្ធការ ។ ប៉ុន្តែអាជ្ញាកណ្ដាលអាចមិនព្រមទទួលយកឆ្នើនសោះក៏បាន ។ បន្ទុកជាអវសាននៃប្រាក់ប្រដាប់ក្ដី ពោលគឺឆ្នើនអាជ្ញាកណ្ដាល ឆ្នើនអ្នកជំនាញ, ស្មៀន និងអ្នកប្រែភាសា ឆ្នើនសាក្សី តាមគោលការណ៍ត្រូវទារពីគូក្ដីណាដែលចាញ់ ជារបៀបអនុវត្តន៍តាមច្បាប់ធម្មតា ។ អាជ្ញាកណ្ដាលអាចទារយកប្រាក់ខ្លះ ជាខាងដើមនៃសេចក្ដីស៊ើបសួរទុកសម្រាប់នឹងបង់សោហ៊ុយនេះ ។ ប្រាក់នេះត្រូវគូក្ដីចេញស្មើគ្នា ។ បើមានទាស់ទែងគ្នាត្រូវចៅហ្វាងសាលាកំរិតជាប្រញាប់ គ្មានបើកផ្លូវឧទ្ធរណ៍ ។ ការព្រមទទួលការតំណែងនេះ បណ្ដាលឲ្យមានកាតព្វកិច្ច ត្រូវចុះហត្ថលេខាលើលិខិតណាដែលត្រូវមានហត្ថលេខាអាជ្ញាកណ្ដាលនោះ ព្រមទាំងលើសាលក្រម បើមិនព្រមទេត្រូវមានទោសមិនបានប្រាក់ឆ្នើន និងបាត់បង់សិទ្ធិធ្វើជាអាជ្ញាកណ្ដាល ។ ទោសនេះត្រូវចុះផ្សាយតាមទម្រង់ដែលមានសំដែងនៅមាត្រា ១១ ។

## ផ្នែកទី ៣

## ការសម្រេច កិច្ចសម្រេច

មាត្រា ១៤.– អាជ្ញាកណ្ដាលមិនអាចនឹងធ្វើបេសកកម្មខ្លួន មុននឹងបានទទួលសម្បថសច្ចា សេចក្ដីដូចមានខាងក្រោម នៅចំពោះមុខសាលាដំបូងជំរះទេ ត្រូវធ្វើកំណត់កត់ហេតុនៅពេលស្បថនេះមួយ ហើយសេចក្ដីចំឡងកត់ហេតុនេះមួយច្បាប់ ត្រូវប្រគល់ឲ្យទៅអាជ្ញាកណ្ដាល ទុកបញ្ចូលក្នុងសំណុំរឿង "ខ្ញុំសូមសច្ចាប្រណិធានថាខ្ញុំនឹងបំពេញបេសកកម្មខ្ញុំដោយភក្ដីភាព និងពិនិត្យដោយសុចរិត នូវមធ្យោបាយគូសញ្ញា និងកាត់សេចក្ដីជាអញ្ញត្រកិត និងតាមឥស្សរភាព និងលាក់បិទបាំងការសម្ងាត់នៃសេចក្ដីពិភាក្សា" ។

សម្បថនេះ ត្រូវស្បថតាមទម្រង់ការដែលមានបញ្ញត្តក្នុងក្រមពិភាក្សាព្រហ្មទណ្ឌ ។
អាចមិនទទួលសម្បថបាន :

១ – អាជ្ញាកណ្តាល ក្នុងសម្បថដែលទទួលសម្បថមួយឆ្នាំម្តង ។

២.– ចៅក្រមដែលរើសធ្វើជាអាជ្ញាកណ្តាល ។

៣.– អាជ្ញាកណ្តាលឯណា ដែលគ្មានចុះឈ្មោះក្នុងបញ្ជីដែលមានសំដែងនៅមាត្រា ១១ ដែលគូសញ្ញាមិនបានឲ្យធ្វើសម្បថសច្ចាជាដាច់ខាតតាមលាយលក្ខណ៍អក្សរ ។

មាត្រា ១៥.– អាជ្ញាកណ្តាលកោះហៅគូក្តី និងសាក្សីមកចំពោះមុខខ្លួន តាមសំបុត្រប៉ារ៉េក ដែលមានម្ទាន់ដៃទទួល ។

គូក្តីត្រូវជូនលិខិតទាំងឡាយ ដែលអាជ្ញាកណ្តាលយល់ឃើញថាគួរយកមកពិនិត្យ ដើម្បីជឿការជាក់ ។ គូក្តីនេះ អាចមានមនុស្សជាជំនួយ ឬជាតំណាងបាន ។ ប៉ុន្តែ បើមានបង្គាប់ឲ្យចូលផ្ទាល់ខ្លួន គូក្តីនេះគោងតែចូលខ្លួន ។

មាត្រា១៦.– ក្នុងករណី ដែលមានគូក្តីណាមួយដែលបានកោះហៅត្រឹមត្រូវ ហើយមិនចូលខ្លួន នោះត្រូវចាត់ឲ្យអាជ្ញាសាលាកោះហៅជាថ្មី រួចហើយជំនុំជំរះចេញសាលក្រម ដែលទុកជាសាលក្រមចំពោះមុខតាមកស្តាងដែលគូក្តីខាងម្ខាងជូន ។

បើមានសាក្សីណាមួយ ដែលបានទទួលដីកាកោះពីអាជ្ញាសាលាជាត្រឹមត្រូវហើយ ។ នៅតែពុំព្រមចូល ចាងហ្វាងក្រុមអាជ្ញាកណ្តាលអាចប្តឹងទៅចាងហ្វាងសាលាតុលាការ សុំឲ្យអនុវត្តន៍មាត្រា ៣០២, ៣០៥, ៣០៦, នៃក្រមពិភាក្សារដ្ឋប្បវេណី ។ ចាងហ្វាងជំនុំជំរះចេញសាលក្រមតាមពាក្យបណ្តឹងនេះ ហើយមិនអាចព្រមចាត់ការតាមបណ្តឹងទេ បើសាក្សីពិតជាបានទទួលដីកាកោះផ្ទាល់ពីអាជ្ញាសាលាហើយ ។

មាត្រា ១៧.– អាជ្ញាកណ្តាលអាចយកអ្នកប្រែភាសា និងស្មៀនមួយនាក់ មកអមធ្វើការជាមួយបាន ស្មៀននេះត្រូវធ្វើសេចក្តីកត់ហេតុអំពីការពិភាក្សាដែលត្រូវចាងហ្វាង

ក្រុមអាជ្ញាកណ្តាលចុះហត្ថលេខា ។ ស្មៀននេះត្រូវចេះនិយាយ ចេះមើល និងចេះសរសេរភាសាដែលបានរើសសម្រាប់ពិភាក្សា ។

អាជ្ញាកណ្តាលទាំងឡាយ អាចចាត់អាជ្ញាកណ្តាលណាមួយក្នុងពួកខ្លួនដើម្បីឲ្យធ្វើអង្កេតស៊ើបសួរ ។ អាជ្ញាកណ្តាលនេះ អាចតាំងអ្នកជំនាញបាន ។ គ្រប់តែកិច្ចស៊ើបសួរ ត្រូវធ្វើតាមកំណត់កត់ហេតុមួយ ដែលត្រូវចុះហត្ថលេខានៃអាជ្ញាកណ្តាលដែលចាត់ ឬភាគច្រើននៃពួកអាជ្ញាកណ្តាល ។

មាត្រា១៨ — បើមិនបានព្រមព្រៀងផ្សេងពីនេះទេ ក្រុមអាជ្ញាកណ្តាលត្រូវមានអាជ្ញាកណ្តាលមួយចាស់ជាងគេ ជាអធិបតី ។

មាត្រា១៩.— គ្រប់តែសេចក្តីសម្រេចនៃអាជ្ញាកណ្តាល ត្រូវធ្វើតាមមតិភាគច្រើន ហើយត្រូវធ្វើជាកម្មវត្ថុនៃសាលក្រមជាលាយលក្ខណ៍អក្សរមួយ ដែលយ៉ាងតិចត្រូវមានភាគច្រើននៃអាជ្ញាកណ្តាលចុះហត្ថលេខា ។ សេចក្តីចំឡងមួយច្បាប់នៃការសម្រេចនេះដែលមានចុះហត្ថលេខាបានហ្មង ត្រូវប្រគល់ឲ្យគូក្តីម្នាក់ៗ ឬអ្នកតំណាងគូក្តីនេះ ។ សាលក្រមដើម ត្រូវដំកល់ទុកក្នុងសំណុំរឿង ។

មាត្រា២០.— ក្នុងករណីដែលមានសំឡេងស្មើគ្នា ដែលអាចបណ្តាលឡើងបាន:

១.— កាលណាបើអាជ្ញាកណ្តាលមានចំនួនគូ ។

២.— កាលណាបើអាជ្ញាកណ្តាលមានចំនួនសេស ។

បើប្រសិនជារកភាគច្រើនមិនបាន ឧទាហរណ៍: បើប្រសិនជាក្នុងអាជ្ញាកណ្តាល ៣ នាក់ អាជ្ញាកណ្តាលនីមួយៗ ប្រកាន់យកផ្លូវដោះស្រាយដោយខ្លួនៗ ឬបើមាន ៥ នាក់ ពីរនាក់ប្រកាន់ផ្លូវដោះស្រាយមួយ ពីរនាក់ទៀតប្រកាន់ផ្លូវដោះស្រាយមួយទៀត អ្នកទី ៥ ប្រកាន់ផ្លូវដោះស្រាយមួយទៀត នោះត្រូវធ្វើសេចក្តីកត់ហេតុមួយ ពីការខ្វែងយោបល់គ្នានេះ ។ សេចក្តីកត់ហេតុនេះត្រូវចុះយោបល់ផ្សេងៗ និងបង្ហាញហេតុ-ផលនៃអាជ្ញាកណ្តាលផង ។

ចាងហ្វាងសាលាជំនុំជំរះ ដែលទទួលបណ្តឹងដូចមានបញ្ញត្តិនៅមាត្រា ១១ ត្រូវតាំងអាជ្ញាកណ្តាលក្រៅមួយ តាមបញ្ជីដែលមានសំដែងនៅមាត្រា ១.១ អាជ្ញាកណ្តាលក្រោយនេះ ត្រូវរិះរកផ្លូវដោះស្រាយយ៉ាងណា ឲ្យបានភាគច្រើនទៅលើផ្លូវដោះស្រាយណាមួយ ក្នុងកំណត់ពេលមួយខែ ក្រោយថ្ងៃដែលតាំងខ្លួន ។

អាជ្ញាកណ្តាលក្រៅ នឹងអាចយកផ្លូវដោះស្រាយណាមួយបានលុះតែបានពិគ្រោះជាមួយនឹងអាជ្ញាកណ្តាលឯទៀតដែលប្រជុំគ្នា ឬដែលបានកោះហៅជាត្រឹមត្រូវ ត្រូវធ្វើសេចក្តីកត់ហេតុមួយពីរឿងពិគ្រោះនេះ ដែលត្រូវអាជ្ញាកណ្តាលក្រៅ នឹងយ៉ាងតិចភាគច្រើននៃអាជ្ញាកណ្តាលចុះហត្ថលេខាផង ។

## ផ្នែកទី ៤

## អំពីការវិវាទជាតុលាការ ដែលអាចបណ្តាលឲ្យមានឡើង ក្នុងឱកាស សម្រេចកិច្ចសម្រប

មាត្រា ២១.– ចាងហ្វាងសាលាជំនុំជំរះ ដែលមានសមត្ថកិច្ចត្រូវជំនុំជំរះការវិវាទ គឺចាងហ្វាងសាលាជំនុំស៊ីវិល ឬសាលាពាណិជ្ជកម្មតាមភេទរឿងវិវាទដែលទាស់គ្នា ។

សាលាតុលាការដែលមានសមត្ថកិច្ចតាមនាទី ត្រូវកំរិតតាមច្បាប់ធម្មតា លើកលែងតែមានព្រមព្រៀងអំពីសមត្ថកម្មប្លែក ដូចមានសំដែងនៅមាត្រា ៨ ។

មាត្រា ២២ – គូក្តីណាមួយដែលកោះហៅជាគូក្តី នៅចំពោះមុខក្រុមអាជ្ញាកណ្តាល អាចប្តឹងថាក្រុមនេះគ្មានសមត្ថកិច្ចបាន ដោយអាងថាគ្មានកិច្ចសម្របក្តី ដោយថាកិច្ចសម្របនេះជាអសារឥតការក្តី ឬដោយអាងថា រឿងវិវាទនេះ មិនត្រូវនៅក្នុង ខ នៃកិច្ចសម្របក្តី ។

ការតវ៉ាអំពីសាបសូន្យសមត្ថកម្ម ត្រូវធ្វើជាមុនសេចក្តីដោះស្រាយខាងក្នុងបើពុំនោះត្រូវផុតលេតដូរតវ៉ា ការសាបសូន្យសមត្ថកិច្ចនេះ ត្រូវជាកម្មវត្ថុសាលក្រមមួយ ។ ការតវ៉ានឹងសាលក្រមនេះត្រូវធ្វើទៅចំពោះមុខចាងហ្វាងសាលាជំនុំជំរះ ចាងហ្វាងនេះត្រូវសម្រេចសេចក្តីជាប្រញាប់ ។

ការឧទ្ធរណ៍នេះ ដែលត្រូវធ្វើតាមពាក្យមួយប្តឹងចាងហ្វាង ត្រូវឲ្យដំណឹងទៅគូក្តីឯទៀត និងទៅចាងហ្វាងក្រុមអាជ្ញាកណ្តាល ។ ការឧទ្ធរណ៍នេះ មានផលនឹងបង្អាក់រឿងនៅចំពោះមុខអាជ្ញាកណ្តាល រយៈពេលដែលទុកសាលក្រម អាជ្ញាកណ្តាលជាស្ថាពរនោះ ត្រូវផ្អាកចាំសម្រេចរឿងឧទ្ធរណ៍សិន ។

រយៈពេលដែលត្រូវប្តឹងឧទ្ធរណ៍ ត្រូវកំណត់ ៣ ថ្ងៃៈពេញ ក្រោយថ្ងៃសាលក្រម ។ អមនឹងពាក្យបណ្តឹងឧទ្ធរណ៍ ត្រូវជូនសេចក្តីចំលងសាលក្រមដែលមានចាងហ្វាងចុះហត្ថលេខាផង ហើយដែលបានប្រគល់ឲ្យអ្នកសុំឧទ្ធរណ៍ និងសេចក្តីចំលងកិច្ចសម្របមួយច្បាប់ ។

មាត្រា ២៣.– ចាងហ្វាងសាលាជំនុំ ត្រូវជំនុំជំរះសម្រេចតាមសាលក្រម ដែលអាចតវ៉ាចំពោះសាលាវិនិច្ឆ័យបាន តែមិនអាចផ្អាករឿងទេ ។

មាត្រា ២៤.– គូក្តីឯណាមួយ អាចចូលពាក្យប្តឹងដល់ចាងហ្វាង សុំឲ្យចុះរូបមន្តបរិវត្តន៍លើសាលក្រមបាន ។ អ្នកនេះត្រូវជូនជាមួយនឹងពាក្យនូវសេចក្តីចំលងនៃសាលក្រមអាជ្ញាកណ្តាលមួយដែលបានប្រថាប់ត្រាជាត្រឹមត្រូវ ។

ចាងហ្វាងត្រូវសំរេចអំពីរូបមន្តនេះ តាមសាលក្រមមួយដែលត្រូវសរសេចក្តីខាងក្រោមពាក្យបណ្តឹង គូក្តីណាដែលសង្ស័យថានឹងទទឹងជាងគេត្រូវកោះហៅមកផង ។

សាលក្រមនេះ ដែលអាចតវ៉ាទៅសាលាវិនិច្ឆ័យបានតែម្តងមួយ មានអំណាចតែកាត់ថា យល់ព្រម ឬមិនយល់ព្រមឲ្យចុះរូបមន្តបរិវត្តន៍នេះ ។

បើព្រមឲ្យសម្រេច ក្រឡាបញ្ជីត្រូវចុះរូបមន្តបរិវត្តន៍ នៅខាងក្រោមសេចក្ដីចំឡងសាលក្រម ។

មាត្រា ២៥.– មិនត្រូវអនុញ្ញាតឲ្យចុះរូបមន្តបរិវត្តន៍ បើកាលណា៖

១) – អាជ្ញាកណ្ដាលរំលងអំណាច ដែលបានបើកឲ្យក្នុងកិច្ចសម្រេច ។

២).– សាលក្រមបានកាត់ ក្រោយរយៈពេលដែលកំរិតមុន ឬយកអាជ្ញាកណ្ដាលក្រៅពីអាជ្ញាកណ្ដាលដែលបានតាំងឲ្យកាត់សេចក្ដី ។

៣.– មានបំពារបំពានទៅលើច្បាប់រៀបរយសាធារណៈផង ។

៤.– រឿងវិវាទ ប៉ះពាល់ដល់ការរៀបរយសាធារណៈផង ។

៥.– មានការបំពារបំពាន ទៅលើទម្រង់សំខាន់ ចំពោះមុខអាជ្ញាកណ្ដាល ហើយការបំពារបំពាននេះ ធ្វើឲ្យខូចប្រយោជន៍គូក្ដីដែលតវ៉ា ។

មាត្រា ២៦.– មុននឹងសុំឲ្យចុះរូបមន្តបរិវត្តន៍ គូក្ដីណាដែលយល់ឃើញថា សាលក្រមនោះចូលក្នុងករណីអសារឥតការណាមួយ ដែលមានសំដែងនៅមាត្រា ២៥ អាចធ្វើពាក្យប្ដឹងតាំងហ្វាងសុំឲ្យបដិសេធចោលបាន ។

តាំងហ្វាងសំរេចចេញសាលក្រម គូក្ដីឯទៀតនឹងអាជ្ញាកណ្ដាលត្រូវកោះហៅមកផង ។ មានតែផ្លូវតវ៉ាដល់សាលាវិនិច្ឆ័យមួយទេដែលអាចធ្វើបាន ការតវ៉ានេះមិនអាចផ្អាករឿងបានឡើយ ។

មាត្រា ២៧.– ក្នុងករណីទាំងអស់ ដែលមានបញ្ញត្តនៅមាត្រា ២២ នឹង ២៦ នៃព្រះរាជក្រមនេះ អ្នកដើមបណ្ដឹងមានពុត ដែលធ្វើបណ្ដឹងដល់តាំងហ្វាងសាលា តែដើម្បីឲ្យបន្ទាយរឿងឲ្យវែងឆ្ងាយទៅទៀត អាចត្រូវទោសឲ្យសងជម្ងឺចិត្ត តាមពាក្យបណ្ដឹងគូក្ដីម្ខាងទៀតបាន ។

ទោសដូចគ្នានេះ ត្រូវមានដល់គូក្តីណាដែលមានពុតអាក្រក់ ហើយធ្វើឲ្យពន្យាពេល ដោយមិនព្រមទទួលសម្រេចភ្លាមៗ នៅសាលក្រមអាជ្ញាកណ្តាល ដែលតមកទៀតពិនិត្យឃើញថាបានការ ។

មាត្រា ២៨.– សំណុំរឿងត្រូវមាន ៖

១.– សេចក្តីចំឡងកិច្ចសម្រេច ដែលមានហត្ថលេខាគូក្តីទាំងអស់ ។

២.– សេចក្តីស្រង់កំណត់កត់ហេតុ ស្តីអំពីការទទួលសម្បថសច្ចានៃអាជ្ញាកណ្តាលម្នាក់ៗ បើប្រសិនជាមិនបានរួចអំពីសម្បថតាមច្បាប់ ឬដោយគូសញ្ញាយល់ព្រមទេ ។

៣.– សេចក្តីកត់ហេតុការពិភាក្សា ដែលមានចុះហត្ថលេខាចាងហ្វាងក្រុមអាជ្ញាកណ្តាល ។

៤.– លិខិតដើមនៃសេចក្តីសម្រេចនីមួយៗ នៃអាជ្ញាកណ្តាល ដែលមានអាជ្ញាកណ្តាលទាំងឡាយ ឬភាគច្រើននៃអាជ្ញាកណ្តាលចុះហត្ថលេខា ។

៥.– សេចក្តីស្រង់សាលក្រមនីមួយៗ ដែលចាងហ្វាងសាលាតុលាការបានសម្រេច ។

សំណុំរឿងនេះ ដែលមានចុះលេខទីផ្ចុះបញ្ជីសារពើភ័ណ្ឌ ត្រូវចាងហ្វាងក្រុមអាជ្ញាកណ្តាលយកទៅដាក់ទុក នៅមន្ទីរក្រឡាបញ្ជីតុលាការក្នុងខែថ្ងៃដែលដំនុំជំរះចេញសាលក្រមជាស្ថាពរ ។ សំណុំរឿងនេះ ត្រូវបង្ហាញពកដការកាន់អំណាចតុលាការ កាលណាពកដការនេះទារ ។ រូបមន្តបរិវត្តន៍ត្រូវស្នុកក្នុងកំណត់មួយឆ្នាំ គិតពីថ្ងៃចេញសាលក្រម បើពុំនោះទេត្រូវផុតកំណត់ ។

មាត្រា ២៩.– ការបដិសេធជាអសារឥតការ នៅសាលក្រមអាជ្ញាកណ្តាល តាមហេតុដែលមានសំដែងនៅមាត្រា ២៥ ឬការមិនយល់ព្រមឲ្យរូបមន្តបរិវត្តន៍នោះ បណ្តាលឲ្យបដិសេធកិច្ចសម្រេចជាអសារឥតការ ។ គូក្តីមានសិទ្ធិនឹងប្តឹងសាលាតុលាការតាម

ច្បាប់ធម្មតា ឬនឹងធ្វើកិច្ចសម្រេចថ្មីមួយទៀត ទុកណាជាមានកម្មវត្ថុវិវាទដូចគ្នាក៏បាន ។ ប៉ុន្តែអាជ្ញាកណ្តាលថ្មី ត្រូវយកក្រៅពីអាជ្ញាកណ្តាលដែលបានចេញសាលក្រមបដិសេធ បើពុំនោះទេត្រូវទុកជាអសារឥតការ ។

មាត្រា ៣០.– ទោះយ៉ាងណាក៏ដោយ ហើយដោយគូភាគីទាំងឡាយចេញឈ្មួលចាន់ហ្វាន់. អាចបង្គាប់ឲ្យអ្នកប្រែភាសាក្នុងសម្បថដែលខ្លួនជ្រើសរើសឲ្យប្រែលិខិតទាំងឡាយក្នុងសំណុំរឿង ។

រូបមន្តបរិវត្តន៍ នឹងអាចចុះលើសាលក្រមអាជ្ញាកណ្តាលដែលតែងជាភាសាបរទេសបាន លុះត្រាតែបានប្រែសេចក្តីសាលក្រមនោះជាភាសាខ្មែរ នៅខាងក្រោមលិខិត ។

## ផ្នែកទី ៥

## អំពី ខសម្រេច

មាត្រា ៣១.– ក្នុងបទពាណិជ្ជកម្មជាដាច់ខាត គូសញ្ញាអាចចុះក្នុងកិច្ចសន្យារបស់ខ្លួននូវខសម្រេច គោលគឺការសន្យាថា ព្រមយករឿងទាស់ទែងទាំងអស់ ឬរឿងទាស់ទែងតាមបែបដែលមានកំរិត ដែលកើតមានឡើងអំពីការសម្រេចកិច្ចសន្យានេះ នៅចំពោះមុខអាជ្ញាកណ្តាល ។

មាត្រា ៣២.– ភស្តុតាងខសម្រេច ត្រូវមានក្នុងសេចក្តីបញ្ជាក់ដោយច្បាស់លាស់ក្នុងកិច្ចសន្យា ដែលគូសញ្ញាទាំងអស់បានចុះហត្ថលេខាជាដាច់ខាត ។

ខសម្រេចនេះឲ្យផលទាំងបង្ខំឲ្យគូសញ្ញាចុះហត្ថលេខាលើកិច្ចសម្រេចមួយ បើកាលណាមានកើតទាស់ទែងគ្នា ដែលគូសញ្ញាមិនអាចនឹងសម្រុះសម្រួលបានទេ បើគ្មានយកអ្នកក្រៅ ។

មាត្រា ៣៣.– កាលណាគូសញ្ញាណាមួយ នៃកិច្ចសន្យាដែលមានខសម្រប ចង់ប្រើខសម្របនេះ គូសញ្ញានេះត្រូវឲ្យដំណឹងទៅគូសញ្ញាម្ខាងទៀត ឬគូសញ្ញាទាំងឡាយឯទៀត ដែលមានទាក់ទងតាមសំបុត្រប៉ោកេ មានបង្កាន់ដៃទទួល ឬតាមរយៈអាជ្ញាសាលា ថាខ្លួនទុកកំណត់ពេលថ្ងៃ ដើម្បីប្តឹងចាងហ្វាងសាលាពាណិជ្ជកម្ម តាមពាក្យមួយដែលខ្លួនលើករឿងអាសារឥតការនៃខសម្រប ឬនៃកិច្ចសន្យា មកនិយាយ ឬក៏ថាខ្លួនទទឹងទាស់អំពីខសម្រប ឬកិច្ចសន្យានេះ ឬថាខ្លួនយល់ឃើញថា មិនអាចយកខសម្របមកអនុវត្តន៍ក្នុងរឿងវិវាទនេះបានឡើយ ។

មាត្រា ៣៤.– បើគូសញ្ញាម្ខាងមិនប្រើសិទ្ធិដែលមានបើកឲ្យតាមមាត្រា ៣៣ ទេ ខសម្របដែលគូសញ្ញាម្ខាងយកមកអាងត្រូវទុកជាបានការ លើកលែងតែរឿងវិវាទនោះ មិនមែនជារឿងដែលគេអាចធ្វើកិច្ចសម្របបាន ។

មាត្រា ៣៥.– លុះបានឲ្យដំណឹងទៅគូសញ្ញាម្ខាង តាមរយៈអាជ្ញាសាលាហើយ ពាក្យបណ្តឹងដែលចំឡើយបានចូលប្តឹង ឲ្យផលទឹងផ្អាក់រឿងផ្សះផ្សារបស់អាជ្ញាកណ្តាល រហូតដល់ចាងហ្វាងសាលាតុលាការជំនុំជំរះអំពីដំឡៃទឹងជវៈភាពនៃខសម្របនោះ ។

សាលក្រមចាងហ្វាងសាលា តក់បានតែត្រឹមសាលាវិនិច្ឆ័យ ហើយមិនត្រូវផ្អាកការសម្រេចទេ ។

សិទ្ធិនៃគូសញ្ញា ត្រូវកំណត់តាមមាត្រា ២៦ នឹង ២៩ នៃព្រះរាជក្រមនេះ ។

មាត្រា ៣៦.– បើក្នុងខសម្រប គ្មានញ្ជាក់អំពីចំនួនអាជ្ញាកណ្តាល ហើយបើប្រសិនជាទៅពេលតែងកិច្ចសម្រប គូសញ្ញាមិនស្រុះស្រួលគ្នាក្នុងរឿងនេះ គូសញ្ញានិមួយៗ ត្រូវរើសយកអាជ្ញាកណ្តាលមួយដោយសេរី អាជ្ញាកណ្តាលទាំងនេះ ត្រូវរើសយកប្រធានមួយ ក្នុងបញ្ជីដែលមានសំដែងនៅមាត្រា ១១ ។

បើអាជ្ញាកណ្តាលមិនមូលមតិគ្នាទេនោះ ចាងហ្វាងសាលាតុលាការ ត្រូវរើសតាំងដូចមានបញ្ញត្តក្នុងមាត្រា ២០ ។

## ផ្នែកទី ៦

# អវសានបញ្ញត្តិ

មាត្រា ៣៧.— អាជ្ញាកណ្ដាលអាចប្រកែកមិនទទួលតំណែង បានតែដោយហេតុដែលមានបញ្ញត្តក្នុងច្បាប់ ដែលកើតមានឡើងតាំងពីបានតាំងខ្លួន ឬដែលមិនបានដឹងនូវពេលតាំង ។

មាត្រា ៣៨.— អំពីការប្រកែកមិនព្រមទទួលតំណែង ត្រូវជំនុំជំរះដូចមានបញ្ញត្តនៅមាត្រា ២២, ទឹង ២៣ ។

អាជ្ញាកណ្ដាលដែលប្រកែក ត្រូវយកជំនួសវិញ តាមសេចក្ដីសម្រេចអាជ្ញាកណ្ដាលឯទៀត អាជ្ញាកណ្ដាលនេះ ត្រូវរើសយកក្នុងបញ្ជីដែលមានសំដែងនៅមាត្រា ១១ តាមភាគពួកកិច្ច ។ ក្នុងករណីដែលអាជ្ញាកណ្ដាលទាំងឡាយមិនស្រុះស្រួលគ្នា បើឈ្មោះណាមួយ ត្រូវធ្វើដូចមានបញ្ញត្តនៅមាត្រា ៣៦ ដើម្បីតាំងអាជ្ញាកណ្ដាលក្រៅមួយ ។

មាត្រា ៣៩.— ពាក្យបណ្ដឹងដែលចូលប្ដឹងដល់ចាងហ្វាងសាលាតុលាការ អំពីឧប្បត្តិហេតុអ្វីមួយនោះ មានផលផ្អាកទឹងពេលវេលាដែលអាជ្ញាកណ្ដាលត្រូវជំនុំជំរះ លុះត្រាតែបានសម្រេចអំពីឧប្បត្តិហេតុនេះសិន ។

មាត្រា ៤០.— កាលណាគូក្ដីប្ដឹងតុលាការ អំពីរឿងរ៉ាវណាមួយ ដោយរំលងលើកិច្ចសម្រេច ឬលើខសម្រេច សាលាតុលាការត្រូវប្រកាសថា ខ្លួនគ្មានសមត្ថកិច្ច បើប្រសិនជាគូក្ដីឯណាមួយបានលើកយកកិច្ចសម្រេច ឬខសម្រេចនេះមកនិយាយមុនទឹងឆ្លើយដោះសាជាខាងក្នុង ។

មាត្រា ៤១.– សាលក្រមដែលសាលាតុលាការប្រកាសថា គ្មានសមត្ថកិច្ច យ៉ាងនេះ អាចតវ៉ាបានគ្រប់ផ្លូវតាមច្បាប់ធម្មតា ។ ប៉ុន្តែការតវ៉ាចំពោះសាលាវិនិច្ឆ័យ មិនអាចផ្អាកឡើងទេ ។

មាត្រា ៤២.– ការរឹងទទឹងមិនព្រមចុះហត្ថលេខាលើកិច្ចសម្រេចដែលធ្វើដោយ បរិវត្តន៍តាម ខ សម្រេចនោះ ត្រូវធ្វើឲ្យមានសមត្ថកិច្ច សាលាជំនុំពាណិជ្ជកម្មច្បាប់ធម្មតា មិនគិតអំពីប្រាក់ជម្ងឺចិត្តផង ។

មាត្រា ៤៣.– ត្រូវបន្ថែមទៅលើមាត្រា ៣៦ នៃក្រមពិភាក្សារដ្ឋប្បវេណី នូវវគ្គទី ២ ដែលមានសេចក្តីដូចតទៅ :

មាត្រា ៣៦.– វគ្គទី ២ សិទ្ធិដែលមានបញ្ញត្តនៅមាត្រា ៣៥ និង ៣៦ វគ្គទី ១ ត្រូវប្រើប្រាសតាមបញ្ញត្តិនៃចំពូក ៦ ច្បាប់ពាណិជ្ជកម្ម ។

មាត្រា ៤៤.– មាត្រា ៧៩៥ សព្វថ្ងៃនៃច្បាប់ពាណិជ្ជកម្មត្រូវទុកជាមោឃ ។ មាត្រា ៧៩៦ និង ៧៩៧ ប្រែទៅជាមាត្រា ៧៩៥ និង ៧៩៦ ។

មាត្រា ៤៥.– ព្រះរាជក្រមនេះ រហូតដល់មាត្រា ៤២ គិតទាំងមាត្រានេះផង បង្កើតទៅជាចំពូក ៦ នៃច្បាប់ពាណិជ្ជកម្ម ដែលឲ្យឈ្មោះថា "អំពីការផ្សះផ្សានៃអាជ្ញាកណ្តាល" ។

មាត្រាទាំងឡាយនៃចំពូកនេះ ត្រូវដាក់លេខតអំពីមាត្រា ៧៩៦ ទៅ ។

ធ្វើក្នុងព្រះបរមរាជវាំងក្រុងភ្នំពេញ ថ្ងៃ ២ ១១ ១ ឆ្នាំមមីឆស័ក ព.ស. ២៤៩៧ ត្រូវនឹងថ្ងៃទី ៦ ធ្នូ គ.ស. ១៩៥៤ ។

ព្រះហស្តលេខា :

ន. សីហនុ

## ព្រះរាជក្រមលេខ ៩៧៦-ន.ស.

បានទ្រង់យល់ រដ្ឋធម្មនុញ្ញព្រះរាជអាណាចក្រ ។

បានទ្រង់យល់ ព្រះរាជក្រមលេខ ១៧១-ន.ស. ចុះថ្ងៃទី ១៤ មេសា គ.ស. ១៩៤៦ ស្ដីអំពីមុខក្រសួងសមាជិកព្រះរាជរដ្ឋាភិបាល ។

បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ ៥២១-ន.ស. ចុះថ្ងៃទី ២៦ សីហា គ.ស. ១៩៥៤ ស្ដីពីតាំងគណៈរដ្ឋមន្ត្រី ។

បានទ្រង់យល់ពិធីសារ ស្ដីអំពីប្រគល់ក្រមអាកាសយានស៊ីវិល ។

បានទ្រង់យល់យោបល់ នៃក្រុមប្រឹក្សាជាតិ ។

គណៈរដ្ឋមន្ត្រី បានយល់ព្រមផង ។

ត្រាស់បង្គាប់ ដូចមានខាងក្រោម :

មាត្រាតែ ១.— ទំរាំងបានប្រកាសឲ្យប្រើច្បាប់ទាំងបទបញ្ញាខ្មែរ ស្ដីអំពីក្រមអាកាសយានស៊ីវិល, ត្រូវដំកល់បទបញ្ញាបារាំងទាំងឡាយ ស្ដីពីរឿងនេះ ទុកប្រើជាបណ្ដោះអាសន្នតទៅទៀត ។

ធ្វើនៅព្រះបរមរាជវាំងចតុមុខក្រុងភ្នំពេញ នៅថ្ងៃទី ២ ១១ ៗ ១ ឆ្នាំមមីឆស័ក ព.ស. ២៤៩៧ ត្រូវនឹងថ្ងៃទី ៦ ធ្នូ គ.ស. ១៩៥៤ ។

ព្រះហស្តលេខា :

ន. សីហនុ